# លក្ខន្តិកៈ

# ក្រុមជួយខ្លួនឯង

## ភូមិកន្លែងរមាស ឃុំពេជ្រមុន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

### ១. គោលបំណងនៃការបង្កើតក្រុមជួយខ្លួនឯង

ការបង្កើតក្រុមជួយខ្លួនឯង គឺមានគោលបំណងផ្តល់ឱ្យអ្នកភូមិទាំងអស់នៅក្នុងភូមិកន្លែងរមាស ឃុំពេជ្រមុន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ពង្រឹង និងពង្រីកនូវចំណងសាមគ្គីភាព ការទទួលខុសត្រូវ និងការចែករំលែកជួយគ្នាទៅវិញទៅមក សំដៅឈានទៅរកការកែលំអកំរិតជីវភាពរស់នៅរបស់ខ្លួន តាមរយៈការចូលរួមទុន និងរៀបចំផែនការរួមគ្នា។

### ២. ដំណើរការបង្កើតក្រុមជួយខ្លួនឯង

ដើម្បីធានាបាននូវភាពជោគជ័យនៅក្នុងដំណើរការក្រុមជួយខ្លួនឯង ប្រជាពលរដ្ឋនៅក្នុងភូមិគោលដៅ ជាអ្នកផ្តួចផ្តើមគំនិត ពិភាក្សានូវរាល់តំរូវការ លក្ខ័ណ្ឌនានាសំរាប់បង្កើត និងដំណើរការក្រុមជួយខ្លួនឯង ដោយមានការចូលរួមសំរបសំរួល និងជួយពីក្រុមប្រឹក្សាឃុំពេជ្រមុន្នី និងបុគ្គលិកអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍។

### ៣. អំពីសមាជិកភាពរបស់ក្រុមជួយខ្លួនឯង

ប្រជាពលរដ្ឋដែលមានជីវភាពក្រលំបាក ដែលស្ម័គ្រចិត្ត និងមានការតាំងចិត្តខ្ពស់អនុវត្តតាមលក្ខន្តិកៈ និងគោលការណ៍ទាំងឡាយរបស់ក្រុម នឹងត្រូវបានស្វាគមន៍អោយចូលរួមជាសមាជិករបស់ក្រុមជួយខ្លួនឯង។ មានតែសមាជិកតែម្នាក់ប៉ុណ្ណោះ នៅក្នុងមួយគ្រួសារ ដែលត្រូវបានអនុញ្ញាតិអោយចូលរួមជាសមាជិកក្រុមជួយខ្លួនឯង។

ការចូលជាសមាជិកក្រុមជួយខ្លួនឯង ត្រូវមានបំពេញទំរង់បែបបទដែលផ្តល់អោយដោយអ្នកដឹកនាំក្រុម។

### ៤. អំពីរចនាសម្ព័ន្ធរបស់ក្រុមជួយខ្លួនឯង

ក្រុមជួយខ្លួនឯង មានសមាជិកចន្លោះពី១០-១៥នាក់។ ក្នុងករណីដែលមានប្រជាពលរដ្ឋលើសពីនេះ បានស្ម័គ្រចិត្តចូលរួមក្នុងក្រុម ក្រុមជួយខ្លួនឯងអាចត្រូវបានបង្កើតទៅជាពីរ រឺបីក្រុម យោងទៅតាមចំនួនអ្នកចូលរួមទាំងនោះ។

នៅក្នុងក្រុមនីមួយៗ ត្រូវជ្រើសរើសអ្នកដឹកនាំក្រុម ដែលមានសមាសភាពចំនួន ៣រូប គឺប្រធាន១រូប អនុប្រធាន១រូប និងហិរញ្ញិកក្រុម១រូប។ អ្នកដឹកនាំក្រុមទាំងបីរូបនេះ ត្រូវបានជ្រើសរើសឡើងដោយការបោះឆ្នោតពីសមាជិកទាំងអស់របស់ក្រុម ដែលមានអាណត្តិរយៈពេល ១ឆ្នាំ។

ក្រៅពីអ្នកដឹកនាំក្រុម ក្រុមជួយខ្លួនឯងក៏ត្រូវបានរៀបចំអោយមានជាទីប្រឹក្សាចំនួន ១ រឺ២នាក់ ដែលជាតំណាងក្រុមប្រឹក្សាឃុំ ដើម្បីជួយផ្តល់យោបល់ និងតាមដានមើលនូវរាល់ដំណើរការរបស់ក្រុម។

## ៥. អំពីតួនាទី និងការទទួលខុសត្រូវ

### ក. តួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុម :

- បង់ប្រាក់សន្សំចូលក្នុងក្រុមជារៀងរាល់ខែ តាមពេលវេលា និងចំនួនកំណត់របស់ក្រុម
- ចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកដឹកនាំក្រុម
- ចូលរួមគោរពអោយបានខ្ជាប់ខ្ជួននូវលក្ខន្តិកៈ និងគោលការណ៍នានាដែលសំរេចដោយក្រុម

### ខ. តួនាទី និងការទទួលខុសត្រូវរបស់ប្រធានក្រុម :

- ជាអ្នកដឹកនាំ និងសំរបសំរួលនូវរាល់ដំណើរការសកម្មភាពនៅក្នុងក្រុម
- ជាតំណាងក្រុម ដើម្បីធ្វើការទំនាក់ទំនង ជួបប្រាស្រ័យ និងចុះហត្ថលេខាលើសេចក្តីព្រមព្រៀងនានារបស់ក្រុម
- ផ្តួចផ្តើម និងដឹកនាំសមាជិកក្រុមនៅក្នុងរៀបចំប្រជុំ ធ្វើផែនការសំរាប់ក្រុម
- ធានានូវភាពរីកចំរើនទាំងផ្នែកទុន និងសកម្មភាពរបស់ក្រុម
- សំរបសំរួល និងដោះស្រាយនូវបញ្ហានានាដែលកើតមាននៅក្នុងក្រុម

### គ. តួនាទី និងការទទួលខុសត្រូវរបស់អនុប្រធានក្រុម :

- ជាតំណាងរបស់ក្រុមនៅក្នុងករណីប្រធានក្រុមអវត្តមានមិនអាចបំពេញការងារសំរាប់ក្រុមបាន
- ចូលរួមនៅក្នុងរាល់ដំណើរការដឹកនាំក្រុមជាមួយប្រធាន និងហិរញ្ញិករបស់ក្រុម

### ឃ. តួនាទី និងការទទួលខុសត្រូវរបស់ហិរញ្ញិកក្រុម :

- ជាតំណាងរបស់ក្រុម នៅក្នុងថែរក្សាទុន រៀបចំបញ្ជីចំណូល ចំណាយ បញ្ជីចូលរួមទុន បញ្ជីខ្ចីសំរាប់ក្រុមទាំងមូល
- ចូលរួមនៅក្នុងរាល់ដំណើរការដឹកនាំក្រុមជាមួយប្រធាន និងអនុប្រធានរបស់ក្រុម

### ង. តួនាទី និងការទទួលខុសត្រូវរបស់ទីប្រឹក្សាក្រុម :

- ជាអ្នកផ្តល់យោបល់ដល់អ្នកដឹកនាំ និងសមាជិកក្រុមទាំងមូល សំដៅធ្វើអោយការគ្រប់គ្រង និងដំណើរការក្រុមប្រព្រឹត្តិទៅដោយជោគជ័យ
- តាមដានឃ្លាំមើលជាប្រចាំនូវរាល់ដំណើរការសកម្មភាពរបស់ក្រុម និងជួយអ្នកដឹកនាំក្រុមនៅក្នុងអនុវត្តលក្ខន្តិកៈ និងគោលការណ៍នានារបស់ក្រុមអោយបានខ្ជាប់ខ្ជួន។

## ៦. អំពីការបង់ប្រាក់សន្សំសំរាប់ក្រុម

នៅបន្ទាប់ពីក្រុមត្រូវបានបង្កើតឡើង សមាជិកក្រុមគ្រប់រូប ត្រូវមានកាតព្វកិច្ចបង់ប្រាក់សន្សំចូលក្នុងក្រុមជាទៀងទាត់នៅរៀងរាល់ថ្ងៃទី ២០ នៃខែនីមួយៗ ក្នុងបរិមាណជាកំណត់ចំនួន ២០០០ រៀល ក្នុងមួយគ្រួសារ ។

សមាជិកក្រុម ក៏អាចបង់ប្រាក់សន្សំចូលក្នុងក្នុងក្រុមជាដំណាក់កាល៧ផងដែរដោយចាប់ផ្តើមពីថ្ងៃទី០១ និងបញ្ចប់នៅត្រឹមថ្ងៃទី ២០ សំរាប់ខែនីមួយៗ ដែលក្នុងមួយដំណាក់កាល៧មិនត្រូវតិចជាង៥០០រៀលឡើយ ។

ក្នុងករណីដែលសមាជិកក្រុមមានបំណងចង់បង្កើននូវបរិមាណប្រាក់សន្សំ ត្រូវមានការយល់ព្រម និងសំរេចពីក្រុមទាំងមូលជាមុនសិន ដោយមានធ្វើកំណត់ហេតុជាលាយល័ក្ខអក្សរសំរាប់អនុវត្ត ។

## ៧. ការថែរក្សា និងប្រើប្រាស់ប្រាក់សន្សំរបស់ក្រុម

ហិរញ្ញិកក្រុម ជាអ្នកមានកាតព្វកិច្ចប្រមូល និងថែរក្សានូវប្រាក់សន្សំពីសមាជិកទាំងអស់របស់ក្រុម ។

នៅមុនពេលកំណត់ប្រមូលប្រាក់សន្សំថ្ងៃចុងក្រោយមកដល់យ៉ាងហោចណាស់៣ថ្ងៃ ហិរញ្ញិក ដោយរួមជាមួយប្រធាន និងអនុប្រធាន ក្រុម ត្រូវធ្វើសេចក្តីជូនដំណឹងក្រើនរំលឹកដល់សមាជិកទាំងអស់អោយត្រៀមខ្លួនសំរាប់បង់ប្រាក់សន្សំចូលក្នុងក្រុម ។ ការជូនដំណឹងនេះ អាចធ្វើឡើងដោយរៀបចំការប្រជុំរួម រឺការដើរតាមគ្រប់ផ្ទះរបស់សមាជិកក្រុម ។

ដើម្បីធានាសុវត្ថិភាពសំរាប់ក្រុម ប្រាក់ទាំងអស់របស់ក្រុម អាចត្រូវបានថែរក្សាដោយមនុស្សពីរនាក់ផ្សេងគ្នា ក្នុងនោះមានហិរញ្ញិក១នាក់ រួមជាមួយនឹងប្រធាន រឺអនុប្រធានក្រុម១នាក់ទៀត ដោយមានចាក់សោចំនួន២ផ្សេងគ្នា តែកូនសោត្រូវបានរក្សាទុកតែមួយប្រភេទប៉ុណ្ណោះ ក្នុងមនុស្សម្នាក់។ ក្នុងករណីដែលផ្ទះប្រធាន រឺអនុប្រធាន រឺហិរញ្ញិកក្រុមមិនធានានូវសុវត្ថិភាពក្នុងការថែរក្សាទេ ហឹបប្រាក់ក្រុម ត្រូវថែរក្សាទុកនៅក្នុងផ្ទះរបស់សមាជិកណាម្នាក់ដែលគិតថានឹងមានសុវត្ថិភាពគ្រប់គ្រាន់ ។

សមាជិកទាំងអស់របស់ក្រុម មានសិទ្ធិគ្រប់គ្រាន់ នៅក្នុងការសួរនាំ និងទទួលបានពីពតិមានបរិមាណទុនដែលមាននាពេលបច្ចុប្បន្នរបស់ក្រុម ការពិនិត្យមើលបញ្ជី និងរបាយការណ៍នានារបស់ក្រុម ។

ទុនដែលសន្សំបានរបស់ក្រុម អាចត្រូវបានចាប់ផ្តើមសំរាប់យកទៅប្រើប្រាស់នៅពេលដែលក្រុមមានទុនចាប់ពីចំនួន ១០០ ០០០ រៀល (ដប់ម៉ឺនរៀល) ឡើងទៅ ក្នុងបុព្វហេតុសំខាន់ៗដូចខាងក្រោម :

- ការផ្តល់អោយខ្ចីដល់សមាជិកក្រុមដើម្បីជួយសំរួលការខ្វះខាតក្នុងជីវភាពក្នុងករណីមានគ្រាអាសន្នបន្ទាន់ (គ្រោះថ្នាក់ចរាចរ, បុណ្យសព, ព្យាបាលជំងឺស្រួចស្រាវ,....)
- ការបង្កើតជាមុខរបរ ដើម្បីរកប្រាក់ចំណូលសំរាប់សមាជិកក្រុម រឺសំរាប់ក្នុងក្រុមទាំងមូល (ទិញមីក្រូជួល, តុការ, ជំនួញស្រូវ, ធនាគារស្រូវ, ធនាគារជ្រូក-គោ, ការលក់ដូរ,....)
- សំរាប់ការចំណាយផ្នែករដ្ឋបាល ក្រដាសស្នាម និងការលើកទឹកចិត្តដល់អ្នកដឹកនាំក្រុម ដែលបានបំពេញការងារជូនក្រុមទទួលបានជោគជ័យ ។

មិនត្រូវប្រើប្រាស់ប្រាក់សន្សំអោយអស់ពីក្នុងហឹបប្រាក់របស់ក្រុមឡើយ គឺយ៉ាងហោចណាស់ត្រូវរក្សាទុកប្រាក់

អោយមានចំនួន ១០% នៅក្នុងហិបប្រាក់សន្សំ ដើម្បីឆ្លើយតបតំរូវការបន្ទាន់ៗនានាដែលអាចកើតមានឡើង។

ក្នុងករណីដែលក្រុមរីកចំរើន និងមានប្រាក់សន្សំច្រើន ប្រាក់ទាំងនោះត្រូវបានពិចារណាដាក់នៅក្នុងធនាគារ ដែលស្ថិតនៅជិតភូមិជាងគេបំផុត ហើយដែលមានសុវត្ថិភាព។

ការប្រើប្រាស់ប្រាក់សន្សំរបស់ក្រុម គឺសំរាប់តែផលប្រយោជន៍របស់សមាជិកក្រុមតែប៉ុណ្ណោះ លើកលែងតែសមាជិកក្រុមមិនត្រូវការ រឺករណីប្រាក់សន្សំរបស់ក្រុមមានបរិមាណច្រើន រឺករណីមានការសំរេចដោយឡែកផ្សេងទៀតដែលធ្វើឡើងដោយក្រុមទាំងមូល។

រាល់ការប្រើប្រាស់ប្រាក់សន្សំរបស់ក្រុមទោះបីក្នុងបុព្វហេតុណាមួយក៏ដោយ ត្រូវតែមានលក្ខ័ណ្ឌ និងគោលការណ៍ច្បាស់លាស់ដោយឡែកមួយផ្សេងទៀតដែលមានការព្រមព្រៀងរវាងក្រុម និងសមាជិកដែលទទួលប្រាក់សន្សំសំរាប់ប្រើប្រាស់ ដើម្បីធានានូវភាពគង់វង្ស និងរីកចំរើនរបស់ក្រុម។

ការផ្តល់ប្រាក់សន្សំសំរាប់សមាជិកក្រុមខ្ចី ត្រូវគ្មាន រឺមានអត្រាការប្រាក់យ៉ាងច្រើនបំផុតត្រឹម២% យោងទៅតាមស្ថានភាពក៏រិតជីវភាពរស់នៅរបស់សមាជិកក្រុមនោះ។ ចំពោះការផ្តល់ប្រាក់សន្សំសំរាប់ប្រជាពលរដ្ឋដែលមិនមែនជាសមាជិកក្រុម ត្រូវមានអត្រាការប្រាក់ចាប់ពី៣%ឡើងទៅ ដោយមានការសំរេចពីក្រុមទាំងមូល។

## ៨. អំពីការប្រជុំក្រុម

ក្រុមជួយខ្លួនឯង ត្រូវរៀបចំការប្រជុំនៅរៀងរាល់១ខែម្តង នៅក្នុងកំឡុងពេល៥-១០ថ្ងៃ នៃថ្ងៃប្រមូលប្រាក់សន្សំចុងក្រោយរបស់ក្រុម។ ការប្រជុំនេះ ធ្វើឡើងដោយមានការចូលរួមពីអ្នកដឹកនាំក្រុម សមាជិកក្រុម ទីប្រឹក្សាក្រុម ដោយផ្តោតទៅលើរបៀវរៈសំខាន់ៗដូចខាងក្រោម :

- របាយការណ៍ពីលទ្ធផលនៃការប្រមូលប្រាក់សន្សំពីសមាជិកក្រុមប្រចាំខែ
- របាយការណ៍ពីបរិមាណប្រាក់សន្សំរបស់ក្រុមដែលមានរហូតមកដល់បច្ចុប្បន្ន
- ពិភាក្សា និងដោះស្រាយនូវកិច្ចការផ្សេងៗទាក់ទងនឹងការគ្រប់គ្រង និងសកម្មភាពរបស់ក្រុម, ការប្រើប្រាស់ប្រាក់សន្សំរបស់ក្រុម។
- ការបង្កើត កែប្រែនូវលក្ខន្តិកៈ គោលការណ៍នានាសំរាប់ក្រុម

ការប្រជុំនេះអាចធ្វើសេចក្តីសំរេចផ្សេងៗបាន លុះត្រាតែមានសមាជិកចូលរួមយ៉ាងតិចចំនួន ២ភាគ៣ នៃសមាជិកសរុប ហើយការសំរេចចិត្ត ត្រូវធ្វើឡើងដោយផ្អែកទៅតាមមតិភាគច្រើន។

## ៩. អំពីពិន័យ និងទណ្ឌកម្មសំរាប់អ្នកប្រព្រឹត្តខុស

ក្នុងករណីដែលអ្នកដឹកនាំក្រុម អសមត្ថភាព អសកម្ម មានគំនិតមិនស្មោះត្រង់ រឺប្រព្រឹត្តិកំហុសឆ្គងដល់ក្រុម សមាជិកក្រុមទាំងអស់ដោយមានការ ជួយពីទីប្រឹក្សាក្រុម អាចរៀបចំធ្វើការប្រជុំ និងបោះឆ្នោតដកសេចក្តីទុកចិត្តពីអ្នកដឹកនាំក្រុមទាំងនោះមុនអាណត្តិបាន រួចជ្រើសរើសអ្នកដឹកនាំថ្មីមកជំនួសអោយស្របតាមលក្ខន្តិកៈរបស់ក្រុម។ ក្នុង

ករណីដែលមានកំហុសធ្ងន់ធ្ងរទាក់ទងដល់ភាពស្មោះត្រង់ចំពោះក្រុម កិត្តិយស រឺប្រាក់សន្សំរបស់ក្រុម ក្រោយពីបោះឆ្នោតដកសេចក្តីទុកចិត្តហើយ អ្នកដឹកនាំក្រុមទាំងនោះនឹងត្រូវបានបណ្តេញចេញពីក្រុម និង/រឺសងនូវរាល់ការខូចខាតទាំងអស់របស់ក្រុមមកក្រុមវិញ។

សមាជិកក្រុម អាចត្រូវបានបណ្តេញចេញពីក្រុម ក្នុងករណីដែលក្រុមរកឃើញកំហុសស្តីពីភាពមិនស្មោះត្រង់ ខកខានមិនបានបង់ប្រាក់សន្សំចូលក្នុងក្រុមចំនួន២ខែជាប់គ្នា, ខកខានមិនបានសងប្រាក់ដែលខ្លួនបានខ្ចីលើសពីរយៈពេល២ខែតាមការកំណត់, ខកខានមិនបានចូលរួមក្នុងការប្រជុំក្រុមចំនួន ៣ដងជាប់ៗគ្នា ព្រមទាំងករណីផ្សេងៗទៀតដែលក្រុមរកឃើញថាជាកំហុសធ្ងន់ធ្ងរ។

ក្នុងករណីដែលសមាជិកក្រុមខកខានមិនបានបង់ប្រាក់សន្សំចំនួន១ខែ សមាជិករូបនោះអាចបង់ប្រាក់សន្សំនៅខែបន្ទាប់បាន ដោយបង់ក្នុងបរិមាណប្រាក់សន្សំសំរាប់រយៈពេល២ខែ រួមជាមួយនឹងប្រាក់ពិន័យចំនួន ២០%នៃប្រាក់សន្សំដែលត្រូវបង់នៅខែទីមួយ (ខែដែលខ្លួនជំពាក់មិនបានបង់ចូលក្នុងក្រុម)។ សមាជិកក្រុមគ្រប់រូប មិនអនុញ្ញាតិអោយខកខានមិនបានបង់ប្រាក់សន្សំចូលក្នុងក្រុមរយៈពេល២ខែជាប់ៗគ្នារួមជាមួយនឹងប្រាក់ពិន័យនោះឡើយ។ ករណីប្រព្រឹត្តិផ្ទុយពីលក្ខ័ណ្ឌនេះ សមាជិករូបនោះត្រូវបានបណ្តេញចេញពីក្រុម។

គ្រប់សមាជិកក្រុមទាំងអស់ ដែលត្រូវបានបណ្តេញចេញ ហើយដែលរយៈពេលចូលជាសមាជិកក្រុមស្ថិតនៅក្រោមរយៈពេល៦ខែ សមាជិករូបនោះមិនត្រូវបានទទួលនូវប្រាក់សន្សំក្នុងករិតណាមួយឡើយសំរាប់ការបណ្តេញចេញនេះ។ ក្នុងករណីដែលសមាជិករូបនោះ បានចូលជាសមាជិកចាប់ពីរយៈពេល៦ខែឡើងទៅ សមាជិករូបនោះត្រូវបានទទួលប្រាក់សន្សំក្នុងករិត៥០% នៃប្រាក់សន្សំដែលខ្លួនបានបង់ចូលចាប់ពីខែទី៦រហូតដល់ខែបណ្តេញចេញ នៅក្រោយ ពីទូទាត់រាល់ការពិន័យនានារួចសំរាប់ក្រុមហើយ។

## ១០. ការលាឈប់ពីសមាជិកក្រុម

ក្នុងករណីដែលសមាជិកក្រុមសុំលាឈប់ពីក្រុមក្នុងមូលហេតុសមស្របផ្សេងៗជាលាយល័ក្ខអក្សរ ហើយដែលរយៈពេលចូលជាសមាជិកក្រុមស្ថិតនៅក្រោមរយៈពេល៦ខែ សមាជិករូបនោះមិនត្រូវបានទទួលនូវប្រាក់សន្សំក្នុងករិតណាមួយឡើយសំរាប់ការលាឈប់របស់ខ្លួន។ ក្នុងករណីដែលសមាជិករូបនោះ បានចូលជាសមាជិកចាប់ពីរយៈពេល៦ខែឡើងទៅ សមាជិករូបនោះត្រូវបានទទួលប្រាក់សន្សំក្នុងករិត៨០% នៃប្រាក់សន្សំដែលខ្លួនបានបង់ចូលចាប់ពីខែទី៦ រហូតដល់ខែដែលសុំលាឈប់។

## ១១. ប្រសិទ្ធិភាពនៃការអនុវត្តលក្ខន្តិកៈក្រុមជួយខ្លួនឯង

លក្ខន្តិកៈក្រុមជួយខ្លួនឯងនេះ មានប្រសិទ្ធិភាពសំរាប់អនុវត្តនៅពេលដែលត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមជួយខ្លួនឯង ប្រធានភូមិ និងប្រធានក្រុមប្រឹក្សាឃុំរួចហើយ។

ការកែប្រែនូវចំនុច រឺខ្លឹមសារដែលមានចែងក្នុងលក្ខន្តិកៈនេះ អាចធ្វើទៅបានតាមរយៈការប្រជុំ និងអនុវត្តនីតិវិធីដូចមានចែងក្នុងចំនុចទី៨ ស្តីពីការប្រជុំ ខាងលើ ។

ធ្វើនៅកន្លែងរមាស, ថ្ងៃទី.....ខែ.........ឆ្នាំ២០០៧

ហត្ថលេខា

**ប្រធានក្រុមជួយខ្លួនឯង**

ថ្ងៃទី.....ខែ.......ឆ្នាំ២០០៧

បានឃើញ និងឯកភាព

**ប្រធានក្រុមប្រឹក្សាឃុំពេជ្រមុន្នី**

ថ្ងៃទី.....ខែ.......ឆ្នាំ២០០៧

បានឃើញ និងឯកភាព

**ប្រធានភូមិកន្លែងរមាស**